ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 5

# ទ្រព្យសកម្មរយៈពេលវែងរក្សាទុកសំរាប់លក់ និងកិច្ចប្រតិបត្តិការមិនបន្ត

## Non-current Assets Held for Sale and Discontinued Operations

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** " ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

៚៙៚

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង“ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ”នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ **ស្តង់ដារគណនេយ្យកម្ពុជា** ដែលរួមមាន“ ***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា*** ” និង “***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម***” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឱ តាយី**

## គោលបំណង

១ គោលបំណងនៃស្តង់ដា ស.រ.ហ.អ.ក នេះគឺដើម្បីបញ្ជាក់ពីគណនេយ្យសម្រាប់ទ្រព្យសកម្មដែលរក្សាទុកសំរាប់លក់ និងការបង្ហាញ និងការលាតត្រដាងពី*ប្រតិបត្តិការមិនបន្ត។* ជាពិសេស ស.រ.ហ.អ.ក តម្រូវថាៈ

(ក) ទ្រព្យសកម្មដែលបំពេញលក្ខណៈវិនិច្ឆ័យ ដែលត្រូវចាត់ថ្នាក់ជាការរក្សាទុក សំរាប់លក់នឹងត្រូវបានវាស់ វែងតាមតម្លៃទាបជាងនៃតម្លៃពិតគណនេយ្យនិង*តម្លៃទីផ្សារ* ដកចេញថ្លៃដើមលក់ និងរំលស់លើទ្រព្យសកម្មនោះដើម្បីឈប់ប្រើ និង

(ខ) ទ្រព្យសកម្មដែលបំពេញលក្ខណៈវិនិច្ឆ័យ ដែលត្រូវចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសំរាប់លក់ដែលនឹង ត្រូវបានដាក់បង្ហាញដាច់ ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលនៃប្រតិបត្តិការមិនបន្ត ដែលត្រូវបានដាក់បង្ហាញដាច់ដោយឡែក នៅក្នុងរបាយ-ការណ៍លទ្ធផលលម្អិត។

## វិសាលភាព

២ សេចក្តីតម្រូវនៃការចាត់ថ្នាក់និងការដាក់បង្ហាញនៃស្តង់ដាស.រ.ហ.អ.ក នេះ អនុវត្តចំពោះគ្រប់ទ្រព្យសកម្ម រយៈពេលវែងដែលបានទទួលស្គាល់ទាំងអស់ និងក្រុមទ្រព្យសកម្មត្រូវលក់ ( ដូចបានកំណត់នៅក្នុងកថាខណ្ឌ៤ ) លើកលែងតែទ្រព្យសកម្មទាំងនោះ ដែលមាននៅក្នុង

កថាខណ្ឌ៥ ដែលត្រូវបន្តវាស់វែងដោយ អនុលោមតាមស្តង់ដារដែលបានកំណត់ចំណាំ។

៣ ទ្រព្យសកម្ម ដែលបានចាត់ថ្នាក់ជារយៈពេលវែង ដោយអនុលោមតាម ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* មិនត្រូវបានចាត់ថ្នាក់ជា *ទ្រព្យសកម្មរយៈខ្លី* រហូតដល់ទ្រព្យសកម្មទាំងនោះបំពេញលក្ខណៈវិនិច្ឆ័យដែលត្រូវចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ដោយអនុលោមតាម ស.រ.ហ.អ.ក នេះ។ ទ្រព្យសកម្មនៃថ្នាក់មួយដែលអង្គភាពមួយជាធម្មតានឹងចាត់ទុកជារយៈពេលវែងនោះគឺត្រូវបានទិញក្នុងគោលបំណងលក់វិញតែប៉ុណ្ណោះ គឺមិនត្រូវបានចាត់ថ្នាក់ជារយៈពេលខ្លីទេលុះត្រាទ្រព្យសកម្មនោះបំពេញលក្ខណៈ វិនិច្ឆ័យដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ដោយអនុលោមតាកថាខណ្ឌ ស.រ.ហ.អ.ក នេះ។

៤ ពេលខ្លះអង្គភាពមួយលក់ចោលទ្រព្យសកម្មរបស់បណ្តុំក្រុមហ៊ុនដែលអាចមានបំណុលខ្លះជាប់ពាក់ព័ន្ធផ្ទាល់រួមជាមួយប្រតិបត្តិការទោល។ ការលក់ចោលរបស់បណ្តុំក្រុមហ៊ុននេះអាចជាក្រុមមួយនៃ*អង្គភាពរក សាច់ប្រាក់* អាចជា អង្គភាពរកសាច់ប្រាក់ទោល ឬជាផ្នែកមួយនៃអង្គភាពរកសាច់ប្រាក់*។ បណ្តុំក្រុមហ៊ុន អាចរួមបញ្ចូលទ្រព្យសកម្ម និងបំណុលទាំងឡាយរបស់អង្គភាព ដោយរួមបញ្ចូលទ្រព្យសកម្មរយៈពេលខ្លី បំណុល និងទ្រព្យសកម្មរយៈពេលខ្លី ដែលត្រូវបានដកចេញដោយកថាខណ្ឌ ៥ ពីសេចក្តីតម្រូវសម្រាប់ការវាស់វែងនៃស្តង់ដា ស.រ.ហ.អ.ក នេះ។ ប្រសិនបើ ទ្រព្យសកម្មរយៈពេលវែងនៅក្នុងវិសាលភាពនៃសេចក្តីតម្រូវ សម្រាប់ការវាស់វែង នៃស្តង់ដារនេះ គឺជាផ្នែកមួយនៃការលក់ចោលបណ្តុំក្រុមហ៊ុន សេចក្តីតម្រូវសម្រាប់ការវាស់វែងនៃ ស.រ.ហ.អ.ក នេះ អនុវត្តចំពោះបណ្តុំ

ក្រុមហ៊ុនទាំងមូល ដូច្នេះបណ្តុំក្រុមហ៊ុនត្រូវបានវាស់វែងតាមតម្លៃទាបជាងនៃតម្លៃពិតគណនេយ្យ និងតម្លៃទីផ្សារដកចេញថ្លៃដើមលក់ ។ សេចក្តីតម្រូវសម្រាប់ការវាស់វែង ទ្រព្យសកម្មនិងបំណុលមួយៗ នៅក្នុងក្រុមទ្រព្យសកម្មត្រូវលក់ ត្រូវបានកំណត់នៅក្នុងកថាខណ្ឌ ១៨ ១៩ និង ២៣។

៥ ការផ្តល់ការវាស់វែងនៃស្តង់ដារនេះ* មិនអនុវត្តចំពោះទ្រព្យសកម្ម ដូចខាងក្រោម ដែលនឹងត្រូវគ្របដណ្តប់ដោយ ស.រ.ហ.អ.ក ដែលបានរាយឈ្មោះខាងក្រោម ជាទ្រព្យសកម្មមួយៗ ឬជាផ្នែកនៃការលក់ចោលនៃបណ្តុំក្រុមហ៊ុនៈ

(ក) ទ្រព្យសកម្មពន្ធពន្យា (ស.គ.អ.ក ១២ *ពន្ធលើប្រាក់ចំណូល*)។

(ខ) ទ្រព្យសកម្មដែលកើតចេញពីអត្ថប្រយោជន៍និយោជិក( ស.គ.អ.ក ១៩ *អត្ថប្រយោជន៍បុគ្គលិក*)។

(គ) ទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* ។

(ឃ) ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានធ្វើគណនេយ្យកម្ម ដោយអនុលោមតាមវិធីសាស្ត្រតម្លៃទីផ្សារស.គ.អ.គ៤០*ទ្រព្យវិនិយោគ*

(ង) ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានវាស់វែងតាមតម្លៃទីផ្សារដកចេញថ្លៃដើមលក់ដោយអនុលោម ស.គ.អ.ក ៤១ *កសិកម្ម*។

(ច) សិទ្ធិតាមកិច្ចសន្យា ក្រោមកិច្ចសន្យាធានារ៉ាប់រងដូចបានកំណត់នៅក្នុង ស.រ.ហ.អ.ក *កិច្ចសន្យាធានារ៉ាប់រង*។

៥ក សេចក្តីតម្រូវសម្រាប់ការចាត់ថ្នាក់ ដាក់បង្ហាញ និងការវាស់វែង នៅក្នុង ស.រ. ហ.អ.ក នេះ ដែលអាចអនុវត្តបានចំពោះទ្រព្យសកម្មរយៈពេលវែង (ឬ ក្រុមទ្រព្យសកម្មត្រូវលក់) ដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម

រក្សាទុកសម្រាប់លក់ក៏អនុវត្តចំពោះទ្រព្យសកម្មរយៈពេលវែង(ក្រុមទ្រព្យសកម្មត្រូវលក់ ) ដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់ការបែងចែកទៅឲ្យម្ចាស់ដែលបំពេញមុខងារជាម្ចាស់ (រក្សាទុកសំរាប់ការបែងចែកទៅឲ្យម្ចាស់)។

៥ខ ស្តង់ដានេះ បញ្ជាក់ពីការលាតត្រដាងដែលបានតម្រូវឲ្យមានទាក់ទងនឹងទ្រព្យសកម្មរយៈពេល (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសំរាប់លក់ ឬជាកិច្ចប្រតិបត្តិការមិនបន្ត។ ការលាតត្រដាងនៅក្នុង ស.រ.ហ.អ.ក ផ្សេងទៀតមិនអនុវត្តចំពោះ ទ្រព្យសកម្មបែបនេះ (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) លុះត្រា ស.រ.ហ.អ.ក ទាំងនោះបានតម្រូវ :

(ក) ការលាតត្រដាងជាក់លាក់ទាក់ទងនឹងទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ឬកិច្ចប្រតិបត្តិការមិនបន្ត ឬ

(ខ) ការលាតត្រដាងអំពីការវាស់វែងទ្រព្យសកម្ម និងបំណុលនៅក្នុងក្រុមទ្រព្យសកម្មត្រូវលក់ ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសេចក្តីតម្រូវសំរាប់ការវាស់វែង ស.រ.ហ.អ.ក ៥ និងការលាតត្រដាងបែបនេះមិនទាន់ត្រូវបានផ្តល់នៅក្នុងកំណត់សម្គាល់ផ្សេងៗចំពោះរបាយ-ការណ៍ហិរញ្ញវត្ថុ។

ការលាតត្រដាងបន្ថែមអំពីទ្រព្យសកម្មមិនបន្ត (ក្រុមទ្រព្យសកម្មត្រូវលក់) ដែលបានចាត់ថ្នាក់ជាការ រក្សាទុកសម្រាប់ ឬកិច្ចប្រតិបត្តិការមិនបន្ត អាចមានភាពចាំបាច់ដើម្បីអនុលោមតាមសេចក្តីតម្រូវទូទៅនៃ ស.គ.អ.ក ១ ជាពិសេសនៅក្នុងកថាខណ្ឌ ១៥ និង ១២៥ នៃស្តង់ដារនោះ។

## ការចាត់ថ្នាក់នៃទ្រព្យកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលរក្សាទុកសម្រាប់លក់ ឬរក្សាទុកសម្រាប់ការបែងចែកទៅឱ្យម្ចាស់

៦ **អង្គភាពមួយត្រូវចាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង (ក្រុមទ្រព្យសកម្មត្រូវលក់) ដែលរក្សាទុក សម្រាប់លក់ប្រសិនបើតម្លៃពិតគណនេយ្យ នឹងត្រូវបានទទួលបានមកវិញជាសំខាន់តាមរយៈប្រតិបត្តិការលក់ ជាជាងតាមរយៈការប្រើប្រាស់បន្ត ។**

៧ ទ្រព្យសកម្ម (ក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានមានសម្រាប់ការលក់បន្ទាន់នៅក្នុងលក្ខខណ្ឌបច្ចុប្បន្ន ដែលជាកម្មវត្ថុតែចំពោះលក្ខខណ្ឌដែលធម្មតា និងជាទំលាប់សម្រាប់ការលក់ទ្រព្យសកម្មបែបនេះ (ការលក់ចោលនៃបណ្តុំក្រុមហ៊ុន ) និងការលក់*មានភវនីយកំរិតខ្ពស់* សំរាប់នេះនឹងជាករណី ។

៨ សម្រាប់ការលក់ដែលនឹងមានភវនីយកំរិតខ្ពស់ កំរិតគណៈគ្រប់គ្រងសមស្របត្រូវមានការប្តេជ្ញាចំពោះផែនការ ដើម្បីលក់ទ្រព្យសកម្ម (ក្រុមទ្រព្យសកម្មត្រូវលក់) និងកម្មវិធីដ៏សកម្មមួយដើម្បីកំណត់ទីតាំង និងបំពេញផែនការត្រូវតែបានផ្តួចផ្តើម។ លើសពីនេះទៅទៀត ការលក់គួរត្រូវបានរំពឹងនឹងបំពេញឱ្យការទទួលស្គាល់ជាការលក់រួចរាល់នៅក្នុងរយៈពេល ១ ឆ្នាំ ចាប់ពីកាលបរិច្ឆេទចាត់ថ្នាក់ លើកលែងដូចបានអនុញ្ញាតដោយកថាខណ្ឌ៩ ហើយសកម្មភាពដែលតម្រូវឱ្យបំពេញផែនការត្រូវបង្ហាញថាវាមិនទំនងថាការផ្លាស់ប្តូរសំខាន់ៗចំពោះ ផែនការនឹងត្រូវបានធ្វើឡើង ឬថាផែនការនឹងត្រូវបានដកចេញមកវិញ។ ភវនីយភាពនៃការអនុម័តរបស់ម្ចាស់ភាគហ៊ុន (ប្រសិនបើបានតម្រូវនៅក្នុងប្រទេស) ត្រូវបានចាត់ទុកជាផ្នែកនៃការវាយតម្លៃថាតើការលក់ មានភវនីយកំរិតខ្ពស់។

៨ក អង្គភាពមួយដែលមានការប្តេជ្ញាចំពោះផែនការលក់ដែលទាក់ទិននឹងការបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវចាត់ថ្នាក់ទ្រព្យសកម្ម និងបំណុលទាំងអស់នៃក្រុមហ៊ុនសម្ព័ន្ធជាការរក្សាទុលសម្រាប់លក់នៅពេលលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុង កថាខណ្ឌ ៦-៨ ត្រូវបាន បំពេញដោយមិនគិតថាតើអង្គភាព នឹងរក្សាភាគកម្មមិនគ្រប់គ្រងនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដើមដំបូងបន្ទាប់ពីការលក់។

៩ ព្រឹត្តិការណ៍ឬហេតុការណ៍អាចពន្យាការិយបរិច្ឆេទ ដើម្បីបំពេញការលក់ក្រោយរយៈពេល ១ឆ្នាំ។ ការពន្យានៃការិយបរិច្ឆេទ ដែលបានតម្រូវឲ្យបំពេញការលក់មិនដកចេញនូវទ្រព្យសកម្មទេ (ការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ពីការចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ប្រសិនបើការពន្យាបានបណ្តាលមកពីព្រឹត្តិការណ៍ឬ ហេតុការណ៍លើសពីការគ្រប់គ្រង និងមានភស្តុតាងថាអង្គភាពនៅតែមានការប្តេជ្ញាចំពោះផែនការ ដើម្បីលក់ទ្រព្យសកម្ម (ឬ ក្រុមទ្រព្យសកម្មត្រូវលក់)។ នេះនឹងជាករណីមួយពេលលក្ខណៈវិនិច្ឆ័យនៅក្នុង ឧបសម្ព័ន្ធ ខ ត្រូវបានបំពេញ។

១០ ប្រតិបត្តិការលក់រួមបញ្ចូលការដោះដូរនៃទ្រព្យសកម្មរយៈពេលវែងសម្រាប់ទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត នៅពេលដែលការដោះដូរមានលក្ខណៈពាណិជ្ជកម្ម ដោយអនុលោមតាម ស.គ.អ.ក ១៦ *ទ្រព្យ រោងចក្រ និងបរិក្ខារ។*

១១ នៅពេលដែលអង្គភាពមួយទិញទ្រព្យសកម្មរយៈពេលវែង(ក្រុមទ្រព្យសកម្មត្រូវលក់) ក្នុងគោលបំណងលក់នៅឆ្នាំបន្តបន្ទាប់តែប៉ុណ្ណោះ អង្គភាពត្រូវចាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង (ការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលរក្សាទុកសម្រាប់លក់នៅកាលបរិច្ឆេទទិញតែប្រសិនបើសេចក្តីតម្រូវ

ចំពោះរយៈពេល ១ឆ្នាំ នៅក្នុងកថាខណ្ឌ ៨ ត្រូវបានបំពេញ (លើកលែងតែមានការអនុញ្ញាតដោយកថាខណ្ឌ៩) និងវាមានភាវនីយកំរិតខ្ពស់ដែលលក្ខណៈវិនិច្ឆ័យផ្សេងៗនៅក្នុងកថាខណ្ឌ៧ និង ៨ ដែលមិនត្រូវបានបំពេញនៅកាលបរិច្ឆេទនោះ នឹងត្រូវ បានបំពេញនៅក្នុងការិយបរិច្ឆេទរយៈពេលខ្លីបន្ទាប់ពីការទិញ (ជាធម្មតានៅក្នុងរយៈពេល៣ខែ)។

១២ ប្រសិនបើ លក្ខណៈវិនិច្ឆ័យនៅក្នុងកថាខណ្ឌ៧និង៨ត្រូវបានបំពេញនៅបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ អង្គភាពមួយ មិនត្រូវចាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ជាការរក្សាទុកសំរាប់លក់នៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនោះពេលដែលបានចេញផ្សាយ។ ប៉ុន្តែនៅពេលដែលលក្ខណៈវិនិច្ឆ័យត្រូវ បានបំពេញបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែនៅមុនពេលការអនុញ្ញាតឲ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវលាតត្រដាងពីព័ត៌មានដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ៤១(ក) (ខ) និង (ឃ) នៅក្នុងកំណត់ សំគាល់។

១២ក ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់បែងចែកទៅឲ្យម្ចាស់ នៅពេលដែលអង្គភាពត្រូវបានសន្យាថានឹងបែងបែងទ្រព្យសកម្ម (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ទៅឲ្យម្ចាស់។ បើនេះនឹងជាករណីនោះ ទ្រព្យសកម្មត្រូវតែមានសំរាប់ការបែងចែកជាបន្ទាន់នៅ ក្នុងលក្ខខណ្ឌបច្ចុប្បន្ន ហើយការបែងចែកត្រូវមានភាវនីយកំរិតខ្ពស់ ។ សម្រាប់ការបែងចែកដែលមានភាវនីយខ្ពស់សកម្មភាពត្រូវបំពេញចំពោះការបែងចែកត្រូវបានបង្កើតឡើង និងគួរត្រូវបានរំពឹងថានឹងបញ្ចប់នៅក្នុងរយៈពេល ១ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចាត់ថ្នាក់ ។ សកម្មភាពទាំងឡាយដែលតម្រូវឲ្យមាននឹងត្រូវបានដកចេញ

វិញ ។ ភាវនីយភាពនៃសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន (ប្រសិនបើបានតម្រូវនៅក្នុងប្រទេសខ្លះ ) គួរត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការវាយតម្លៃពីថា តើការបែងចែកមានភាវនីយកិរិតខ្ពស់ដែរឬទេ ។

## ទ្រព្យសកម្មរយៈពេលវែងដែលនឹងត្រូវបានបោះបង់ចោល

១៣ អង្គភាពមួយ មិនត្រូវចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់នូវទ្រព្យសកម្មរយៈពេលវែង (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលនឹងត្រូវបោះបង់ចោលទេ។ នេះដោយសារសារតម្លៃពិតគណនេយ្យនឹងត្រូវទទួលបានមកវិញតាមរយៈការប្រើប្រាស់បន្ត។ ប៉ុន្តែ ប្រសិនបើ ក្រុមទ្រព្យសកម្មត្រូវលក់ដែលនឹងត្រូវបានបោះបង់ចោល ត្រូវបំពេញលក្ខខណៈវិនិច្ឆ័យនៅក្នុងកថាខណ្ឌ ៣២(ក)-(គ) នោះអង្គភាពត្រូវបង្ហាញលទ្ធផល និងលំហូរសាច់ប្រាក់នៃក្រុមទ្រព្យសកម្ម ត្រូវលក់ជាកិច្ចប្រតិបត្តិការមិនបន្ត ដោយអនុលោមតាម កថាខណ្ឌ៣៣ និង ៣៤ នៅកាលបរិច្ឆេទ ដែលអង្គភាពឈប់ប្រើប្រាស់។ ទ្រព្យសកម្មរយៈពេលវែង (ការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលនឹងត្រូវបោះបង់ចោល បញ្ចូលនូវទ្រព្យសកម្មរយៈពេលខ្លី (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលនឹងត្រូវបានប្រើរហូតដល់ចុងបញ្ចប់នៃអាយុកាលសេដ្ឋកិច្ចរបស់ទ្រព្យសកម្មនោះ និងទ្រព្យសកម្មរយៈពេលវែង(ឬក្រុមទ្រព្យសកម្មត្រូវលក់)ដែលនឹងត្រូវចោលជាជាងការលក់។

១៤ អង្គភាពមួយមិនធ្វើគណនេយ្យកម្មលើទ្រព្យសកម្មរយៈពេលវែង ដែលត្រូវបានយកទៅប្រើប្រាស់បណ្តោះអាសន្ន ទោះបីជាទ្រព្យសកម្មនោះត្រូវបានគេបោះបង់ចោលក៏ដោយ។

**ការវាស់វែងទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់)**

១៥ **អង្គភាពមួយត្រូវវាស់វែងទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់ ) ដែលបានចាត់ថ្នាក់ ជាទ្រព្យរក្សាទុកសម្រាប់លក់តាមតម្លៃទាបជាងនៃតម្លៃពិតគណនេយ្យ និងតម្លៃទីផ្សារដកថ្លៃដើមលក់ ។**

១៥ក **អង្គភាពមួយត្រូវវាស់វែងទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលបាន ចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់បែងចែកទៅឲ្យម្ចាស់តាមតម្លៃទាបជាងនៃតម្លៃពិតគណនេយ្យ និងតម្លៃទីផ្សារដកថ្លៃដើមបែងចែក ។**

១៦ ប្រសិនបើទ្រព្យសកម្មទើបតែទិញថ្មី (ឬក្រុមទ្រព្យសកម្មត្រូវលក់) បំពេញលក្ខណៈវិនិច្ឆ័យដើម្បីចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់( សូមមើលកថាខណ្ឌ ១១) ដោយអនុវត្តកថាខណ្ឌ១៥ នឹងបង្ហាញចេញនៅក្នុងទ្រព្យសកម្ម (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលកំពុងត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូងតាមតម្លៃទាបជាង នៃតម្លៃពិតគណនេយ្យ និងតម្លៃទីផ្សារដកថ្លៃដើមលក់ដែលវាត្រូវបានចាត់ថ្នាក់ (ឧទាហរណ៍ថ្លៃដើម )។ ដូច្នេះហើយ ប្រសិនបើទ្រព្យសកម្ម (ឬក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានទិញជា ជាផ្នែកមួយនៃការបញ្ចូលអាជីវកម្មរួមគ្នា នោះទ្រព្យត្រូវបានវាស់ វែងតាមតម្លៃទីផ្សារដកថ្លៃលក់ ។

១៧ នៅពេលដែលការលក់ ត្រូវបានរំពឹងថានឹងកើតឡើងក្រោយរយៈពេល ០១ឆ្នាំ អង្គភាពត្រូវបានវាស់វែងថ្លៃដើមលក់តម្លៃបច្ចុប្បន្នរបស់គេ។ ការកើនឡើងណាមួយ នៅក្នុងតម្លៃបច្ចុប្បន្ននៃថ្លៃដើមលក់ ដែលកើតចេញ

ពីការកន្លងផុតទៅនៃពេលវេលា ត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាតជាចំណាយហិរញ្ញវត្ថុហិរញ្ញវត្ថុ។

១៨ មុនពេលដែលការចាត់ថ្នាក់លើកដំបូងនៃទ្រព្យសកម្ម (ឬក្រុមទ្រព្យសកម្មត្រូវលក់) រក្សាទុកសំរាប់លក់ នោះតំលៃពិតគណនេយ្យនៃទ្រព្យសកម្ម (ទ្រព្យសកម្ម និងបំណុលសរុបទាំងអស់នៅក្នុងបណ្តុំក្រុមហ៊ុន) ត្រូវតែវាស់វែងដោយអនុលោមតាម ស.រ.ហ.អ.ក ដែលអាចអនុវត្តបានភ្លាម។

១៩ ពេលការវាស់វែងបន្តបន្ទាប់នៃក្រុមទ្រព្យសកម្មត្រូវលក់ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និងបំណុលណាដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសេចក្តីតម្រូវសំរាប់ការវាស់វែងនៃស្តង់ដានេះ ប៉ុន្តែត្រូវបានបញ្ចូលនៅក្នុងក្រុមទ្រព្យសកម្មត្រូវលក់ ដែលបានចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ ត្រូវបានគេវាស់វែងដោយអនុលោមតាម ស.រ.ហ.អ.ក ដែលអាចអនុវត្តបាន មុនតម្លៃទីផ្សារដកថ្លៃដើមលក់នៃក្រុមទ្រព្យសកម្មត្រូវលក់ត្រូវបានវាស់វែងឡើងវិញ។

## ការទទួលស្គាល់ខាតពីការធ្លាក់ចុះតម្លៃ និង ការត្រឡប់វិញ

២០ អង្គភាពមួយត្រូវទទួលស្គាល់ខាតពីធ្លាក់ចុះតម្លៃសម្រាប់ចំណាយដំបូង ឬចំណាយបន្តបន្ទាប់នៃទ្រព្យសកម្ម (ឬ (ឬក្រុមទ្រព្យសកម្មត្រូវលក់) ចំពោះតម្លៃទីផ្សារដកថ្លៃដើមលក់ រហូតដល់ខាតនោះ មិនត្រូវបានគេទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ១៩។

២១ អង្គភាពមួយត្រូវទទួលស្គាល់ចំណេញសម្រាប់ការកើនឡើងតំលៃទីផ្សារដកថ្លៃដើមលក់បន្តបន្ទាប់នៃទ្រព្យសកម្ម ប៉ុន្តែមិនឲ្យលើសតម្លៃពីការធ្លាក់ចុះ

តម្លៃបូកបន្ថែលត្រូវទទួលស្គាល់ដោយអនុលោមតាម ស.រ.ហ.អ.ក នេះ ឬ ដោយអនុលោមតាម ស.គ.អ.ក៣៦ *ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម។*

២២ អង្គភាពមួយត្រូវទទួលស្គាល់ចំណេញចំពោះការកើតឡើងតម្លៃទីផ្សារដក ថ្លៃដើមលក់ឆ្នាំបន្តបន្ទាប់នៃ ការលក់ចោលនៃបណ្តុំក្រុមហ៊ុនៈ

(ក) រហូតដល់ថាចំណេញនោះមិនត្រូវបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ១៩ ប៉ុន្តែ

(ខ) មិនឱ្យលើសពីទឹកប្រាក់ខាតពីការធ្លាក់ចុះតម្លៃបូកបន្ត ដែលត្រូវបានទទួលស្គាល់ ដោយអនុលោមតាម ស.រ.ហ.អ.ក ឬដោយអនុលោមតាម ស.គ.អ.ក ៣៦ នៅលើទ្រព្យសកម្មរយៈពេលវែងដែលស្ថិតនៅក្នុង វិសាលភាពនៃសេចក្តីតម្រូវសម្រាប់ការវាស់វែងនៃ ស.រ.ហ.អ.ក នេះ។

២៣ ការខាតពីការធ្លាក់ចុះតម្លៃ (ឬចំណេញឆ្នាំបន្តបន្ទាប់) ដែលបានទទួលស្គាល់សម្រាប់ការលក់ចោលនៃបណ្តុំក្រុមហ៊ុនត្រូវកាត់បន្ថយ(ឬបង្កើនឡើង) តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មបច្ចុប្បន្ននៅក្នុងបណ្តុំក្រុមហ៊ុនដែលស្ថិតនៅក្នុងវិសាលភាពនៃសេចក្តីតម្រូវសំរាប់វាស់វែងនៃ ស.រ.ហ.អ.ក នេះ តាមលំដាប់លំដោយដែលបានដាក់ចេញនៅក្នុង កថាខណ្ឌ ១០៤(ក) និង (ខ) និង ១២២ នៃ ស.គ.អ.ក ៣៦ (បានកែប្រែនៅក្នុងឆ្នាំ ២០០៤)។

២៤ ចំណេញ ឬខាតដែលពីមុនមិនបានទទួលស្គាល់ត្រឹមកាលបរិច្ឆេទលក់ទ្រព្យសកម្មរយៈពេលវែង (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទឈប់ទទួលស្គាល់។ សេចក្តីតម្រូវដែលទាក់នឹង ការឈប់ទទួលស្គាល់ត្រូវបានចែងនៅក្នុងៈ

(ក) កថាខណ្ឌ ៦៧-៧២ នៃ ស.គ.អ.ក ១៦ (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៣) សំរាប់ទ្រព្យ រោងចក្រ និងបរិក្ខារ និង

(ខ) កថាខណ្ឌ ១១២-១១៧ នៃ ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបី* (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៤) សំរាប់ទ្រព្យសកម្មអរូបី)។

២៥ អង្គភាពមួយមិនត្រូវធ្វើរំលស់ (ឬដករំលស់) ទ្រព្យសកម្មរយៈពេលវែងខណៈពេលដែលទ្រព្យសកម្មនោះត្រូវបានចាត់ថ្នាក់ជាទ្រព្យរក្សាទុកសំរាប់លក់ ឬខណៈពេលដែលទ្រព្យគឺជាផ្នែកមួយនៃការលក់ចោលនៃបណ្តុំក្រុមហ៊ុនដែលបានចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់។ ការប្រាក់ និងចំណាយផ្សេងទៀតដែលបែង ចែកទៅបំណុលរបស់ក្រុមទ្រព្យសកម្មត្រូវលក់ដែលចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់ត្រូវបន្តទទួលស្គាល់ទៀត។

## ការផែនការលក់

២៦ ប្រសិនបើអង្គភាពមួយបានចាត់ថ្នាក់ទ្រព្យសកម្មមួយ (ឬក្រុមទ្រព្យសកម្មត្រូវលក់) ជាទ្រព្យរក្សាទុក សំរាប់លក់ ប៉ុន្តែលក្ខណៈវិនិច្ឆ័យនៅក្នុងកថាខណ្ឌ ៧-៩ មិនបានបំពេញតទៅទៀត អង្គភាពត្រូវបញ្ឈប់ចាត់ថ្នាក់ទ្រព្យសកម្ម (ឬក្រុមទ្រព្យសកម្មត្រូវលក់) ជាទ្រព្យសំរាប់លក់ទៀត។

២៧ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មរយៈពេលវែងដែលឈប់ចាត់ថ្នាក់ជាទ្រព្យរក្សាទុកដើម្បីលក់ (ឈប់បញ្ចូល ក្នុងក្រុមទ្រព្យសកម្មត្រូវលក់ ដែលបានចាត់ថ្នាក់ជាទ្រព្យរក្សាទុកសំរាប់លក់) តាមតម្លៃទាបជាងនេះ

(ក) តម្លៃពិតគណនេយ្យមុនពេលទ្រព្យសកម្ម (ឬក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់ ដែលបានកែសម្រួលចំពោះរំលស់ណាមួយ ឬការវាយតម្លៃឡើងវិញ

ដែលនឹងត្រូវបានទទួលស្គាល់ មានទ្រព្យសកម្ម (ឬក្រុមទ្រព្យ-សកម្មត្រូវលក់) មិនត្រូវបានចាត់ ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់និង

(ខ) ចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញ នៅកាលបរិច្ឆេទនៃការសម្រេចចិត្តបន្តបន្ទាប់មិនលក់*។

២៨ អង្គភាពត្រូវរួមបញ្ចូលការកែសម្រួលណាមួយដែលបានតម្រូវចំពោះតម្លៃពិត គណនេយ្យនៃទ្រព្យសកម្មរយៈពេលវែងដែលឈប់ចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់នៅក្នុងរបាយការណ៍ចំណេញឬខាត* ពីប្រតិបត្តិការកំពុងបន្តនៅក្នុងការិយបរិច្ឆេទ ដែលលក្ខណៈវិនិច្ឆ័យ នៅក្នុងកថាខណ្ឌ ៧-៩ មិនត្រូវបានបំពេញតទៅទៀត។ អង្គភាពត្រូវដាក់បង្ហាញថាការកែសម្រួលចំណងជើងដូចគ្នានៅក្នុងរបាយការណ៍លទ្ធផលលម្អិតដែលបានប្រើដើម្បីបង្ហាញចំណេញឬខាតប្រសិនបើមាន បានទទួលស្គាល់ដោយអនុលោមតាកថាខណ្ឌ ៣៧។

២៩ ប្រសិនបើអង្គភាពមួយផ្លាស់ចេញទ្រព្យកម្មឬបំណុលមួយៗ ពីក្រុមទ្រព្យសកម្មត្រូវលក់ដែលបានចាត់ ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់ទ្រព្យ-សកម្ម និងបំណុលដែលនៅសល់នៃក្រុមទ្រព្យសកម្មត្រូវលក់ដែលនឹងត្រូវលក់ ត្រូវបន្តវាស់វែង ជាបណ្តុំក្រុមហ៊ុន តែប្រសិនបើបណ្តុំក្រុមហ៊ុនបំពេញលក្ខណៈវិនិច្ឆ័យ នៅក្នុងកថាខណ្ឌ៧-៩ ។ ឬម្យ៉ាងវិញទៀត ទ្រព្យសកម្ម រយៈពេលវែងដែលនៅសល់នៃបណ្តុំក្រុមហ៊ុនដែលមួយៗ បំពេញលក្ខណៈវិនិច្ឆ័យដែលនឹងត្រូវបានចាត់ថ្នាក់ជាទ្រព្យរក្សាទុកសម្រាប់លក់ ត្រូវបានវាស់ វែងមួយៗតាមតម្លៃទាបជាងនៃតម្លៃពិតគណនេយ្យ និងតម្លៃទីផ្សារដកថ្លៃដើមលក់នៅកាលបរិច្ឆេទនោះ ។ ទ្រព្យសកម្ម

រយៈពេលវែងណាមួយដែល មិនបំពេញលក្ខណៈវិនិច្ឆ័យត្រូវឈប់ទទួលស្គាល់ជាទ្រព្យរក្សាទុកសម្រាប់លក់ដោយអនុលោមតាមកថាខណ្ឌ ២៦ ។

## ការបង្ហាញនិងការលាតត្រដាងព័ត៌មាន

៣០ **អង្គភាពមួយត្រូវបង្ហាញនិងលាតត្រដាងព័ត៌មានដែលផ្តល់លទ្ធភាព ឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ធ្វើការវាយតម្លៃពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការមិនបន្ត និងការលក់ចោលទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មត្រូវលក់។**

## ការបង្ហាញកិច្ចកិច្ចប្រតិបត្តិការមិនបន្ត

៣១ សម្រាប់គោលបំណងការរាយការណ៍ហិរញ្ញវត្ថុ*សមាសធាតុនៃអង្គភាពមួយ* រួមបញ្ចូលនូវប្រតិបត្តិការ និងលំហូរសាច់ប្រាក់ ដែលអាចត្រូវបានញែកដាច់ពីគ្នាយ៉ាងច្បាស់ ពីផ្នែកនៅសេសសល់របស់អង្គភាព។ម្យ៉ាងវិញទៀត សមាសធាតុនៃអង្គភាពមួយនឹងក្លាយជាអង្គភាពរកសាច់ប្រាក់ ឬក្រុមនៃអង្គភាពរកសាច់ប្រាក់ខណៈពេល ដែលត្រូវបានរក្សាទុកសម្រាប់ប្រើប្រាស់

៣២ កិច្ចប្រតិបត្តិការមិនបន្ត គឺជាសមាសធាតុរបស់អង្គភាពមួយដែលត្រូវបានលក់ចោលឬត្រូវបានចាត់ថ្នាក់ជាសមាសធាតុសម្រាប់លក់ និង

(ក) តំណាងឱ្យខ្សែស្រឡាយអាជីវកម្មធំៗដាច់ដោយឡែក ឬតំបន់ប្រតិបត្តិការតាមភូមិសាស្ត្រ

(ខ) ជាផ្នែកនៃផែនការស្របគ្នាទោលមួយ ដើម្បីលក់ចោលនៃខ្សែស្រឡាយអាជីវកម្មសំខាន់ៗដាច់ឡែកពីគ្នា ឬតំបន់ប្រតិបត្តិការតាមភូមិសាស្ត្រ ឬ

(គ) ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានទិញផ្ដាច់មុខក្នុងគោលបំណង លក់វិញ។

៣៣ អង្គភាពត្រូវលាតត្រដាងៈ

(ក) ទឹកប្រាក់ទោលនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ដែលបានរួមបញ្ចូល ទឹកប្រាក់សរុបនៃៈ

(១) ប្រាក់ចំណេញ ឬខាតក្រោយបង់ពន្ធនៃកិច្ចប្រតិបត្តិការ មិនបន្ត និង

(២) ចំណេញ ឬខាតក្រោយបង់ពន្ធដែលបានទទួលស្គាល់ តាមការវាស់វែងតម្លៃទីផ្សារដកថ្លៃដើមលក់ ឬតាមការលក់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មត្រូវលក់ ដែលបង្កបង្កើតឲ្យមាន កិច្ចប្រតិបត្តិការមិនបន្ត។

(ខ) ការវិភាគនៃទឹកប្រាក់ទោលនៅក្នុង (ក) ចូលទៅៈ

(១) ចំណូល ចំណាយ និងប្រាក់ចំណេញ ឬខាតក្រោយបង់ពន្ធនៃកិច្ចប្រតិបត្តិការមិនបន្ត

(២) ចំណាយពន្ធលើប្រាក់ចំណូលដែលទាក់ទិន ដូចដែលបានតម្រូវដោយកថាខណ្ឌ ៨១ (ជ) នៃស.គ.អ.ក ១២។

(៣) ចំណេញ ឬខាតដែលបានទទួលស្គាល់ តាមការវាស់វែងចំពោះតម្លៃទីផ្សារដកថ្លៃដើមលក់ ឬការលក់ចោលទ្រព្យសកម្មឬក្រុមទ្រព្យសកម្មត្រូវលក់ ដែលបង្កបង្កើតប្រតិបត្តិការមិនបន្ត និង

(៤) ចំណាយពន្ធលើប្រាក់ចំណូលដូចបានតម្រូវ ដោយកថាខណ្ឌ ៨១(ជ) នៃស.គ.អ.ក ១២។

ការវិភាគ អាចត្រូវបានគេដាក់បង្ហាញនៅក្នុងកំណត់សំគាល់ ឬនៅក្នុងរបាយការណ៍លទ្ធលម្អិត។ ប្រសិនបើ ការវិភាគត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍លទ្ធផលសរុប ការវិភាគនោះត្រូវដាក់បង្ហាញនៅក្នុងផ្នែកមួយដែលបានកំណត់ជាការពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការមិនបន្ត ពោលគឺបង្ហាញដាច់ដោយឡែកពីប្រតិបត្តិការបន្ត។ ការវិភាគមិនត្រូវបានតម្រូវឲ្យសំរាប់ការលក់ចោលបណ្តុំក្រុមហ៊ុន ដែលជាក្រុមហ៊ុនសម្ព័ន្ធទើបតែបានទិញថ្មីដែលបំពេញលក្ខណៈវិនិច្ឆ័យដែលត្រូវបានចាត់ថ្នាក់សម្រាប់លក់នៅពេលទិញ (សូមមើលកថាខណ្ឌ១១)។

(គ) លំហូរសាច់ប្រាក់សុទ្ធ ដែលបានបែងចែកទៅឲ្យសកម្មប្រតិបត្តិការ វិនិយោគ និងហិរញ្ញវត្ថុនៃប្រតិបត្តិ មិនបន្ត។ ការលាតត្រដាងទាំងនេះអាចត្រូវបានបង្ហាញនៅក្នុងកំណត់សំគាល់ឬនៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

៣៣ក ប្រសិនបើអង្គភាព បង្ហាញសមាសធាតុនៃប្រាក់ចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ នៃស.គ.អ.ក ១ (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៧) នោះ ផ្នែកមួយដែលបានកំណត់ថាពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការមិនបន្តត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ដាច់ដោយឡែក នោះ។

៣៤ អង្គភាពមួយ ត្រូវបង្ហាញឡើងវិញនូវការលាតត្រដាងទាំងឡាយ នៅក្នុងកថាខណ្ឌ ៣៣ សំរាប់ការិយបរិច្ឆេទមុនដែលបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដូច្នេះការលាតត្រដាងទាំងឡាយនោះទាក់ទិននឹងប្រតិបត្តិការទាំងអស់ ដែលត្រូវបានបញ្ឈប់ត្រឹម ចុងការិយបរិច្ឆេទរាយការណ៍សម្រាប់ការិយបរិច្ឆេទចុងក្រោយបង្អស់ដែលបានបង្ហាញ។

៣៥ ការកែសម្រួល នៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ចំពោះទឹកប្រាក់ដែលបានបង្ហាញពីមុននៅក្នុងកិច្ចប្រតិបត្តិការមិនបន្តដែលមានការពាក់ព័ន្ធ ដោយផ្ទាល់ចំពោះការលក់ចោលនៃកិច្ចប្រតិបត្តិការមិនបន្តនៅក្នុងការិយបរិច្ឆេទមុន ត្រូវបានចាត់ថ្នាក់ដាច់ដោយឡែកនៅក្នុងកិច្ចប្រតិបត្តិការមិនបន្ត។ ប្រភេទនិងទឹកប្រាក់នៃការកែសម្រួលត្រូវបានលាតត្រដាង។ ឧទាហរណ៍នៃហេតុការណ៍ដែលការកែសម្រួលទាំងនេះអាចកើតឡើង
រួមមានដូចខាងក្រោមៈ

(ក) សេចក្ដីសម្រេចនៃភាពមិនប្រាកដប្រជាដែលកើតឡើងពី លក្ខខណ្ឌនៃប្រតិបត្តិការលក់ចោល ដូចជាសេចក្ដីសម្រេចនៃការកែសម្រួល តម្លៃទិញ និងបញ្ហាការសងជាមួយអ្នកទិញ ។

(ខ) សេចក្ដីសម្រេចនៃភាពមិនប្រាកដប្រជាដែលកើតឡើងពី ឬទាក់ទង ដោយផ្ទាល់ទៅនឹងប្រតិបត្តិការរបស់សមាសធា តុមុនពេលលក់ ចោល ដូចជា កាតព្វកិច្ចធានាផលិតផល និងបរិស្ថានដែលបានរក្សាដោយអ្នកលក់

(គ) ការទូទាត់នៃកាតព្វកិច្ចផែនការអត្ថប្រយោជន៍និយោជិក ដោយដឹងថាការទូទាត់មានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រតិបត្តិការលក់។

៣៦ ប្រសិនបើអង្គភាពមួយ ឈប់ចាត់ថ្នាក់សមាសធាតុរបស់អង្គភាពអង្គភាពមួយជាសមាសធាតុរក្សាទុកសម្រាប់លក់ នោះលទ្ធផលនៃប្រតិបត្តិការ នៃសមាសធាតុ ដែលបានដាក់បង្ហាញនៅក្នុងកិច្ចប្រតិបត្តិការមិនបន្តដោយអនុលោមតាមកថាខណ្ឌ ៣៣-៣៥ ត្រូវបានចាត់ថ្នាក់ឡើងវិញ និងបញ្ចូលនៅក្នុងចំណូលពីប្រតិបត្តិការបន្ត សម្រាប់ការិយបរិច្ឆេទទាំងអស់ដែលបាន

បង្ហាញ។ ទឹកប្រាក់សម្រាប់ការិយបរិច្ឆេទមុនៗ ត្រូវបានចាត់ទុកថាបានបង្ហាញឡើងវិញ។

៣៦ក អង្គភាពមួយដែលធានាចំពោះផែនការលក់ដែលពាក់ព័ន្ធនឹងការបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវលាតត្រដាងបង្ហាញព័ត៌មាន ដែលបានតម្រូវនៅក្នុងកថាខណ្ឌ ៣៣-៣៦ នៅពេលដែលក្រុមហ៊ុនបុត្រសម្ព័ន្ធគឺជាក្រុមទ្រព្យសកម្មត្រូវលក់ដែលបំពេញនិយមន័យនៃកិច្ចប្រតិបត្តិការមិនបន្តដោយអនុលោម តាមកថាខណ្ឌ៣២។

## ចំណេញ ឬ ខាតដែលទាក់ទិននឹងប្រតិបត្តិការបន្ត

៣៧ ចំណេញ ឬខាតពេលវាស់វែងទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលបានចាត់ ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ដែលមិនបានបំពេញនិយមន័យនៃកិច្ចប្រតិបត្តិការមិនបន្តត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍ចំណេញ ឬខាតពីប្រតិបត្តិបន្ត។

## ការបង្ហាញទ្រព្យសកម្មរយៈពេលវែង ឬក្រុមទ្រព្យសកម្មត្រូវលក់ ដែលបានចាត់ថ្នាក់ជាការ រក្សាទុកសំរាប់លក់

៣៨ អង្គភាពមួយត្រូវបង្ហាញទ្រព្យសកម្មរយៈពេលវែង ដែលបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ និងទ្រព្យសកម្មនៃក្រុមទ្រព្យសកម្មត្រូវលក់ ដែលបានចាត់ថ្នាក់ជាការរក្សាទុក សម្រាប់លក់ដាច់ដោយឡែកពី ទ្រព្យសកម្មផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ បំណុលនៃក្រុមទ្រព្យសកម្មត្រូវលក់ដែលបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ត្រូវបានដាក់បង្ហាញដាច់ដោយឡែកពីបំណុលផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ទ្រព្យ-

សកម្មនិងបំណុលមិនត្រូវបានកាត់កងនិងត្រូវបានដាក់បង្ហាញជាចំនួនទឹកប្រាក់ទោល។ ថ្នាក់ទ្រព្យសកម្មនិងបំណុលសំខាន់ៗ ដែលបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ត្រូវបានលាតត្រដាងដាច់ ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់ លើកលែងមានការអនុញ្ញាត នៅក្នុងកថាខណ្ឌ៣៩ ។ អង្គភាពមួយត្រូវបានបង្ហាញដាច់ដោយឡែក នូវចំណូលឬចំណាយបូកបន្តដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតទាក់ទិននឹងទ្រព្យសកម្មរយៈពេលវែង (ឬការលក់ចោល នៃបណ្តុំក្រុមហ៊ុន) ដែលបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ។

៣៩ ប្រសិនបើក្រុមទ្រព្យសកម្មត្រូវលក់គឺជាក្រុមហ៊ុនទើបបានទិញថ្មីៗ ដែលបំពេញលក្ខណៈវិនិច្ឆ័យដើម្បី ចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ពេលទិញ(សូមមើលកថាខណ្ឌ១១) ការលាតត្រដាងនៃថ្នាក់សំខាន់ៗ នៃទ្រព្យ-សកម្ម និងបំណុលមិនត្រូវបានតម្រូវឲ្យមាន ។

៤០ អង្គភាពមួយមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ឬបង្ហាញទឹកប្រាក់ឡើងវិញដែលបានបង្ហាញសម្រាប់ទ្រព្យសកម្មរយៈពេលវែង ឬសម្រាប់បំណុលរបស់ក្រុមទ្រព្យសកម្មត្រូវលក់ ដែលបានចាត់ថ្នាក់ជាការរក្សាទុកសំរាប់លក់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទមុនៗ ដើម្បីឆ្លុះបញ្ចាំងពីការចាត់ថ្នាក់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទចុងក្រោយបង្អស់ដែលបានបង្ហាញ ។

## ការលាតត្រដាងបន្ថែម

៤១ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានខាងក្រោម នៅក្នុងកំណត់សំគាល់ នៅក្នុងការិយបរិច្ឆេទដែលទ្រព្យសកម្មរយៈពេល (ឬក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ឬបានលក់:

(ក) ការពិពិណនាពីទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់)

(ខ) ការពិពិណនាពីហេតុការណ៍ និងកាលៈទេសៈនៃការលក់ ឬការនាំដល់ការលក់ចោលនាពេលខាងមុខ និងឥរិយាបទរំពឹងទុក និងពេលវេលានៃការលក់នោះ។

(គ) ចំណេញ ឬខាត ដែលបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ ២០-២២ និង ប្រសិនបើ មិនបានបង្ហាញដាច់ឡែកនៅក្នុងរបាយការណ៍លទ្ធផលលម្អិតដែលបញ្ចូលចំណេញ ឬខាតនោះ

(ឃ) ប្រសិនបើអាចអនុវត្តបាន ចំណែកដែលអាចរាយការណ៍បាន ដែលទ្រព្យសកម្ម (ឬ ការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ត្រូវបានដាក់បង្ហាញដោយអនុលោមតាម ស.រ.ហ.អ.ក ៨ *ចំណែកប្រតិបត្តិការ*

៤២ ប្រសិនបើកថាខណ្ឌ ២៦ ឬកថាខណ្ឌ ២៩ អនុវត្ត នោះអង្គភាពមួយត្រូវលាតត្រដាង នៅក្នុងការិយបរិច្ឆេទនៃសម្រេចចិត្ត ដើម្បីប្តូរផែនការលក់ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ការពិពិណនាពីហេតុការណ៍ និងកាលៈទេសៈដែលនាំដល់ការសម្រេចចិត្ត និងឥទ្ធិពលនៃការសម្រេចចិត្តចំពោះលទ្ធផលនៃប្រតិបត្តិការ សំរាប់ការិយបរិច្ឆេទ និងការិយបរិច្ឆេទមុនៗដែលបានបង្ហាញ។

## អន្តរបញ្ញត្តិ

៤៣ ស.រ.ហ.អ.ក ត្រូវបានអនុវត្តទៅពេលខាងមុខ ចំពោះទ្រព្យសកម្មរយៈពេលវែង (ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលបំពេញលក្ខណៈវិនិច្ឆ័យ ដើម្បីចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ និងប្រតិបត្តិការដែលបំពេញលក្ខណៈវិនិច្ឆ័យដើម្បីចាត់ថ្នាក់ជាកិច្ចប្រតិបត្តិការមិនបន្តបន្ទាប់ពីកាលបរិច្ឆេទប្រសិទ្ធភាពនៃ ស.រ.ហ.អ.ក។ អង្គភាពមួយ អាចអនុវត្តសេចក្តីតម្រូវនៃ ស.រ.ហ.អ.ក ចំពោះទ្រព្យសកម្មរយៈពេលវែង(ឬការលក់ចោលនៃបណ្តុំក្រុមហ៊ុន) ដែលបំពេញលក្ខណៈវិនិច្ឆ័យ ដើម្បីចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ និងប្រតិបត្តិការ ដែលបំពេញលក្ខណៈវិនិច្ឆ័យដើម្បីចាត់ថ្នាក់ជាកិច្ចប្រតិបត្តិការមិនបន្តបន្ទាប់ពីកាលបរិច្ឆេទណាមួយមុនពេលកាលបរិច្ឆេទប្រសិទ្ធនៃ ស.រ.ហ.អ.ក បានផ្តល់ការវាយតម្លៃ និងព័ត៌មានផ្សេងទៀតដើម្បីអនុវត្ត ស.រ.ហ.អ.ក ត្រូវបានទទួលនៅពេលដែលលក្ខណៈវិនិច្ឆ័យទាំងនោះត្រូវបានបំពេញចាប់ពីដំបូង។

## កាលបរិច្ឆេទប្រសិទ្ធភាព

៤៤ អង្គភាពមួយត្រូវអនុវត្ត ស.រ.ហ.អ.ក នេះសម្រាប់គ្រាប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ អង្គភាពត្រូវលាតត្រដាងពីហេតុការនោះ។

៤៤ក ស.គ.អ.ក ១ (ដូចបានកែប្រែក្នុង ឆ្នាំ២០០៧) បានធ្វើវិសោធនកម្មវាក្យសព្ទ ដែលបានប្រើគ្រប់ ស.រ.ហ.អ.ក។ លើសពីនេះទៅទៀតស្តង់ដារ ធ្វើវិសោធនកម្មកថាខណ្ឌ ៣ និង ៣៨ និង បន្ថែមកថាខណ្ឌ ៣៣ក។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំឆ្នាំដែល

ចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាព អនុវត្ត ស.គ.អ.ក ១ (កែប្រែឆ្នាំ២០០៧) សម្រាប់គ្រាមុនវិសោធនកម្ម ត្រូវបានប្រើសម្រាប់គ្រាមុននោះ។

៤៤ខ ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក និងរបាយការណ៍ហិរញ្ញវត្ថុរួម* (ដូចបានកែប្រែនៅក្នុង ឆ្នាំ២០០៨) ដោយបន្ថែមកថាខណ្ឌ ៣៣(ឃ)។ អង្គភាពមួយត្រូវប្រើវិនិសោធនកម្មនោះសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយអនុវត្ត ស.គ.អ.ក ២៧ (បានធ្វើវិសោធនកម្ម ២០០៨) សម្រាប់គ្រាមុន នោះវិសោធនកម្មត្រូវបានប្រើសម្រាប់គ្រាមុន ។ វិសោ-ធនកម្ម ត្រូវបានប្រើត្រឡប់ក្រោយ។

៤៤គ កថាខណ្ឌ៨ក និង ៣៦ក ត្រូវបានបន្ថែមដោយពាក្យ *ការធ្វើឲ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយ នៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពត្រូវប្រើវិសោធនកម្មទាំងនោះ សំរាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។ ការប្រើមុនត្រូវបានអនុញ្ញាត ។ ប៉ុន្តែ អង្គភាពមួយមិនត្រូវបានប្រើវិសោធនកម្មសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ទេលុះ ត្រាតែអង្គភាពក៏ត្រូវអនុវត្ត ស.គ.អ.ក ២៧ (ដូចបានធ្វើវិសោធនកម្មក្នុងខែមករា ឆ្នាំ២០០៨) ។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ អង្គភាពត្រូវលាតត្រដាងពីហេតុការនោះ។ អង្គភាព ត្រូវប្រើវិសោធនកម្មទៅពេលខាងមុខចាប់ពីថ្ងៃដែលអង្គភាពបានប្រើ ស.រ.ហ.អ.ក ៥ លើកដំបូងដែលជាកម្មវត្ថុនៃអន្តរកាល

នៅក្នុងកថាខណ្ឌ ៤៥ នៃ ស.គ.អ.ក ២៧ (ដូចបានធ្វើវិសោធនកម្ម ខែមករា ឆ្នាំ២០០៨)។

៤៤ឃ កថាខណ្ឌ៥ក ១២ក និង ១៥ក ត្រូវបានបន្ថែម និង កថាខណ្ឌ៨ ត្រូវបានធ្វើវិសោធនកម្មដោយ IFRIC 17 *ការបែងចែកទ្រព្យសកម្ម មិនមែនសាច់ប្រាក់ទៅឱ្យម្ចាស់* នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៨។ វិសោធនកម្មទាំងនោះត្រូវបានប្រើទៅពេលខាងមុខចំពោះទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ដែលត្រូវចាត់ថ្នាក់ជាការរក្សាទុកសម្រាប់ការបែងចែកទៅឱ្យម្ចាស់នៅក្នុងគ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ការអនុវត្តត្រឡប់ក្រោយមិនត្រូវបានអនុញ្ញាតទេ។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មសំរាប់គ្រាដែលចាប់ផ្តើមមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ និងក៏ត្រូវប្រើ ស.រ.ហ.អ.ក ៣ *ការបញ្ចូលអាជីវកម្មរួមគ្នា។* (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៨) ស.គ.អ.ក ២៧ (ដូចបានធ្វើវិសោធនកម្ម នៅខែមករា ឆ្នាំ ២០០៨ និង IFRIC 17។

៤៤ង កថាខណ្ឌ៥ខ ត្រូវបានបន្ថែមដោយពាក្យ *ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានផ្សាយនៅក្នុង ខែមេសា ឆ្នាំ២០០៩។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះទៅពេលខាងមុខសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មសម្រាប់គ្រាមុន អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ។

៤៤ច ស.រ.ហ.អ.ក ៩ ដែលបានចេញផ្សាយនៅក្នុងខែតុលា ឆ្នាំ២០១០ បានធ្វើវិសោធនកម្មកថាខណ្ឌ ៥។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះនៅពេល

ដែលអង្គភាពប្រើ ស.រ.ហ.អ.ក ៩ ដូចដែលបានចេញផ្សាយ នៅក្នុងខែតុលា ឆ្នាំ ២០១០។

**ការដកចេញ ស.គ.អ.ក ៣៥**

---

៤៥ ស.រ.ហ.អ.ក នេះជំនួសឲ្យ ស.គ.អ.ក ៣៥ *កិច្ចប្រតិបត្តិការមិនបន្ត*

**ឧបសម្ព័ន្ធ**

**វាក្យស័ព្ទកំណត់និយមន័យរួច**

*ឧបសម្ព័ន្ធនេះគឺជាផ្នែកសំខាន់មួយនៃ ស.រ.ហ.អ.ក*

| | |
|---|---|
| អង្គភាពរកសាច់ប្រាក់ | ក្រុមនៃទ្រព្យសកម្ម ដែលអាចកំណត់បានតូចជាងគេដែលរកបានលំហូរចូលសាច់ប្រាក់ ដែលអាស្រ័យយ៉ាងខ្លាំងពី ការហូរចូលសាច់ប្រាក់ពីទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្ម ផ្សេងទៀត។ |
| សមាសធាតុរបស់អង្គភាព | កិច្ចប្រតិបត្តិការនិងលំហូរសាច់ប្រាក់ដែលអាចត្រូវបានញែកចេញពីគ្នាយ៉ាងច្បាស់ ជាកិច្ចប្រតិបត្តិការ និងសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុពីផ្នែកនៅសល់របស់អង្គភាព។ |
| ថ្លៃដើមលក់ | ជាចំណាយបន្ថែមដែលចូលរួមដោយផ្ទាល់នៅក្នុងលក់ចោលទ្រព្យសកម្ម (ការលក់បណ្តុំក្រុមហ៊ុន) ដោយមិនបញ្ចូលថ្លៃដើមហិរញ្ញវត្ថុនិងចំណាយពន្ធលើប្រាក់ចំណូល។ |

| | |
|---|---|
| ទ្រព្យសកម្មរយៈពេលខ្លី<br>**current asset** | អង្គភាពមួយត្រូវចាត់ថ្នាក់ទ្រព្យសកម្មមួយជាទ្រព្យសក-ម្មរយៈពេលខ្លីនៅពេលៈ<br>(ក) អង្គភាពរំពឹងថានឹងទទួលស្គាល់ទ្រព្យសកម្ម ឬមានបំណងលក់ ឬប្រើប្រាស់វា នៅក្នុងខួបកិច្ចប្រតិ-បត្តិការធម្មតារបស់ខ្លួន។<br>(ខ) អង្គភាពរក្សាទ្រព្យសកម្មគោលបំណងធ្វើពាណិជ្ជ-កម្មជាសំខាន់<br>(គ) អង្គភាពរំពឹងថានឹងទទួលស្គាល់ទ្រព្យសកម្មនៅក្នុងរយៈពេល១២ខែបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ឬ<br>(ឃ) ទ្រព្យសកម្មគឺជាសាច់ប្រាក់ ឬសាច់ប្រាក់សមមូល (ដូចបានកំណត់នៅក្នុង ស.គ.អ.ក ៧) លើកលែងតែទ្រព្យសកម្មត្រូវបានកំហិតពីការដោះដូរ ឬប្រើប្រាស់ដើម្បីទូទាត់សងបំណុល ក្នុងរយៈពេល យ៉ាងហោចណាស់១២ខែបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។ |
| កិច្ចប្រតិបត្តិការមិនបន្ត | ***សមាសធាតុរបស់អង្គភាពមួយ*** ដែលត្រូវបានលក់ចោល ឬ ត្រូវបានចាត់ថ្នាក់សម្រាប់លក់ និងៈ<br>(ក) តំណាងឲ្យខ្សែអាជីវកម្មធំៗសំខាន់ៗ ឬតំបន់កិច្ចប្រតិបត្តិការតាមភូមិសាស្ត្រ<br>(ខ) ជាផ្នែកមួយនៃផែនការទោលដែលសម្របសម្រួលរួចដើម្បីលក់ខ្សែអាជីវកម្មសំខាន់ៗដាច់ដោយឡែក ឬតំបន់កិច្ចប្រតិបត្តិការតាមភូមិភាគ ឬ |

(គ) ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញសម្រាប់គោលបំណងលក់ចេញវិញតែប៉ុណ្ណោះ។

ក្រុមទ្រព្យសកម្មត្រូវលក់ | ក្រុមទ្រព្យសកម្មដែលត្រូវបោះបង់ចោល ដោយការលក់ ឬ បើមិនដូច្នេះទេ ជាក្រុមទ្រព្យសកម្មមួយនៅក្នុងប្រតិបត្តិការទោល និងបំណុលដែលជាប់ទាក់ទងដោយផ្ទាល់ជាមួយនឹងទ្រព្យសកម្មទាំងនោះដែលនឹងត្រូវបានផ្ទេរនៅក្នុងប្រតិបត្តិការ។ ក្រុមទ្រព្យសកម្ម រួមបញ្ចូលមូលនិធិពាណិជ្ជកម្មដែលទទួលបាននៅក្នុង ការបញ្ចូលអាជីវកម្មរួមគ្នាប្រសិនបើក្រុមគឺជា**អង្គភាពរកសាច់ប្រាក់**ដែលមូលនិធិពាណិជ្ជកម្ម ត្រូវបានបែងចែក ដោយអនុលោមតាមសេចក្តីតម្រូវនៃកថាខណ្ឌ ៨០-៨៧ នៃ ស.គ.អ.ក ៣៦ *ការធ្លាក់តំលៃនៃទ្រព្យសកម្ម* (ដូចបានកែប្រែនៅក្នុងឆ្នាំ២០០៨) ឬប្រសិនបើវាជាកិច្ចប្រតិបត្តិការនៅក្នុងអង្គភាពរកសាច់ប្រាក់បែបនេះ។

តម្លៃសមស្រប | ជាចំនួនទឹកប្រាក់ទ្រព្យសកម្មមួយអាចត្រូវបានដោះដូរ ឬ បំណុលត្រូវបានទូទាត់ រវាងភាគីស្ម័គ្រចិត្តនិងមានចំណេះដឹងនៅក្នុងធម្មតា

| | |
|---|---|
| ការធានាទិញរបស់ក្រុមហ៊ុន | ជាកិច្ចសន្យាមួយជាមួយភាគីមិនពាក់ព័ន្ធ ដែលចងភាគីទាំងពីរ និង ជាធម្មតាមានអំណាចតាមផ្លូវច្បាប់ ដែល (ក) បញ្ជាក់រាល់លក្ខខណ្ឌសំខាន់ៗទាំងអស់ រួមបញ្ចូលតម្លៃនិងពេលវេលានៃប្រតិបត្តិការ និង (ខ) រួមបញ្ចូលការមិនលើកទឹកចិត្តសម្រាប់ការមិនអនុវត្តដែលភាពគ្រប់ គ្រាន់ដើម្បីអនុវត្តការងារ**មានភវនីយខ្ពស់** |
| ភវនីយខ្ពស់ | សំខាន់ច្រើនជាង**ភវនីយ** |
| **ទ្រព្យសកម្មរយៈពេលវែង** | ជាទ្រព្យសកម្មដែលមិនបំពេញនិយមន័យរបស់**ទ្រព្យរយៈពេលខ្លី** |
| **ភវនីយ** | ទំនងច្រើនជាងមិនទំនង |
| **តម្លៃអាចទទួលបាន មកវិញ** | តម្លៃខ្ពស់ជាង នៃតម្លៃសមស្របដកចេញនឹងថ្លៃដើមលក់ និងតម្លៃប្រើប្រាស់ |
| **តម្លៃប្រើប្រាស់** | តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតបានប៉ាន់ស្មានរួច ដែលត្រូវបានរំពឹងថានឹងកើតឡើងពីការបន្តប្រើទ្រព្យសកម្ម និងពីការបោះបង់ចោលនៅចុងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម។ |

## ឧបសម្ព័ន្ធ ខ

## សេចក្តីបន្ថែមចំពោះការអនុវត្ត

*ឧបសម្ព័ន្ធនេះគឺជាផ្នែកសំខាន់មួយនៃ ស.រ.ហ.អ.ក.*

### ការពន្យាពេលនៃការិយបរិច្ឆេទដែលបានតម្រូវដើម្បីបំពេញការលក់

ខ១ ដូចបានបង្ហាញនៅក្នុងកថាខណ្ឌ ៩ ការពន្យាពេលនៃការិយបរិច្ឆេទ ដើម្បីបំពេញឱ្យការលក់មិនបានដកចេញ ទ្រព្យសកម្មមួយ ឬក្រុមទ្រព្យសកម្ម) ពីការចាត់ថ្នាក់ សំរាប់លក់ប្រសិនបើការពន្យាត្រូវបានរំខាន ដោយព្រឹត្តិការណ៍ ឬហេតុការណ៍ក្រោយការគ្រប់គ្រងរបស់អង្គភាព និងមានភស្តុតាងគ្រប់គ្រាន់ ដែលអង្គភាពនៅបន្តអនុវត្ត ចំពោះផែនការលក់ទ្រព្យសកម្ម (ឬបណ្តុំទ្រព្យសកម្មត្រូវលក់)។ ការលើកលែងចំពោះសេចក្តីតម្រូវយៈពេល ១ឆ្នាំនៅក្នុងកថាខណ្ឌ៨ ត្រូវអនុវត្តនៅក្នុងស្ថានភាពខាងក្រោម ដែលព្រឹត្តិការណ៍ ឬហេតុការណ៍បែបនេះ កើតមានឡើង:

(ក) នៅកាលបរិច្ឆេទដែលអង្គភាពធានាខ្លួនឯងចំពោះផែនការ ដើម្បីលក់ទ្រព្យសកម្មរយៈពេលវែង (ឬ ក្រុមទ្រព្យសកម្មត្រូវលក់) ដែលអង្គភាពរំពឹងដោយមានហេតុផលត្រឹមត្រូវថា អ្នកផ្សេងទៀត (មិនមែនអ្នកទិញ) នឹងកំណត់លក្ខខណ្ឌលើការផ្ទេរទ្រព្យសកម្ម (ក្រុមទ្រព្យសកម្មត្រូវលក់) ដែលនឹងពន្យាការិយបរិច្ឆេទ ដែលបានតម្រូវឱ្យមានដើម្បីបំពេញការលក់ និង:

(១) សកម្មភាពចាំបាច់ដើម្បីឆ្លើយតបចំពោះលក្ខខណ្ឌទាំងនោះមិនអាចត្រូវបានបង្កើតឡើងរហូតដល់បន្ទាប់ពី *ការធានាទិញរបស់ក្រុមហ៊ុន* ត្រូវបានទទួល និង

(២) ការធានាទិញរបស់ក្រុមហ៊ុនមានភវនីយខ្ពស់ នៅក្នុងរយៈពេល១ឆ្នាំ។

(ខ) អង្គភាពមួយទទួលការធានាទិញរបស់ក្រុមហ៊ុន ហើយជាលទ្ធផលអ្នកទិញ និងអ្នកផ្សេងទៀតកំណត់ លក្ខខណ្ឌមិនបានដឹងមុនពីការផ្ទេរនៃទ្រព្យសកម្មរយៈពេលវែង(ឬក្រុមទ្រព្យសកម្មត្រូវលក់)ដែលគ្រាមុនត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ដែលនឹងពន្យាការិយ-បរិច្ឆេទដែលបានតម្រូវឱ្យមានដើម្បី បំពេញការលក់ និង

(១) សកម្មភាពទាន់ពេលវេលា ដែលចាំបាច់ ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌដែលត្រូវបានប្រើ និង

(២) សេចក្តីសម្រេចគាំទ្រនៃកត្តាពន្យាពេលត្រូវបានគេរំពឹងថាមាន

(គ) ក្នុងកំឡុងការិយបរិច្ឆេទ ១ឆ្នាំ ដំបូង ហេតុការណ៍ទាំងឡាយ ដែលគ្រាមុនត្រូវបានគិតថា នឹងមិនអាចកើតមាន ហើយជាលទ្ធផលទ្រព្យសកម្មរយៈពេលខ្លី (ឬ ក្រុមទ្រព្យសកម្មត្រូវលក់) គ្រាមុនត្រូវបានចាត់ថ្នាក់ជារក្សាទុកសម្រាប់លក់ មិនត្រូវបានលក់នៅចុងការិយ-បរិច្ឆេទនោះទេ និង:

(១) ក្នុងកំឡុងការិយបរិច្ឆេទ១ឆ្នាំដំបូង អង្គភាពធ្វើសកម្មចាំបាច់ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរ នៅក្នុងហេតុការណ៍ទាំងឡាយនោះ។

(២) ទ្រព្យសកម្មរយៈពេលវែង (ឬក្រុមទ្រព្យសកម្មត្រូវលក់) ត្រូវបានដាក់លក់យ៉ាងសកម្មតាម តម្លៃដែលសមរម្យត្រូវបានផ្តល់ឱ្យមានការផ្លាស់ប្តូរ និងក្នុងហេតុការណ៍និង

(៣) លក្ខណៈវិនិច្ឆ័យនៅក្នុងកថាខណ្ឌ ៧ និង ៨ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ